## ២.គោលបំណង និងវិសាលភាពនៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំសំរាប់កំណត់តំបន់អាទិភាពដែលត្រូវដាំឈើ ដែលនៅក្នុងសេចក្តីបរិយាយជាបន្តបន្ទាប់ខាងមុខត្រូវបានហៅថា *គោលការណ៍ណែនាំ* មានគោលដៅបង្កើនវិសាលភាពក្នុងការគ្រប់គ្រងព្រៃដាំ ដោយបានបង្ហាញនូវការពិចារណាដ៏សមហេតុផលក្នុងការកំណត់ទីតាំង ដោយរួមបញ្ចូលទាំងការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធនានា។ គោលការណ៍ណែនាំនេះអាចអនុវត្តបានគ្រប់សកម្មភាពដាំដើមឈើ រួមទាំងការបង្កើតចំការឈើដាំជាទ្រង់ទ្រាយធំ ការស្តារដីព្រៃឈើរេចរិលឡើងវិញ ការដាំឈើដោយសហគមន៍ និងការដាំឈើនៅលើដីចំការជាលក្ខណៈគ្រួសារ។ ឯកសារនេះក៏មានគោលដៅជួយដល់រដ្ឋបាលព្រៃឈើនៅគ្រប់ថ្នាក់ក្នុងការរៀបចំធ្វើផែនការដាំឈើហើយមានលទ្ធភាពចង្អុលបង្ហាញដល់អ្នកវិនិយោគទុន និង អ្នកផ្តល់ជំនួយឱ្យជ្រើសរើសបានទីតាំងដាំឈើដែលសមស្រប។ ការប្រកាន់យកនូវជំរើសនេះនឹងជួយជំរុញឱ្យមានការប្រើប្រាស់ថវិកាចំគោលដៅដែលជាតំបន់អាទិភាពរបស់រាជរដ្ឋាភិបាល ក៏ដូចជារបស់ភ្នាក់ងារផ្តល់ជំនួយ និង ផ្នែកឯកជននានា។

ជំហានជាបន្តបន្ទាប់ដែលបង្ហាញជូនក្នុងឯកសារនេះ ត្រូវបានរៀបចំឡើងដើម្បីតម្រូវតាមសេចក្តីត្រូវការប្រើប្រាស់របស់អ្នកពាក់ព័ន្ធទាំងឡាយក្នុងវិស័យព្រៃឈើ។ ទោះជាយ៉ាងនេះក្តីនៅមានបញ្ហាមួយចំនួនទៀតដែលឋិតនៅក្រៅគោលការណ៍ណែនាំនេះ ប៉ុន្តែក៏ជាកត្តាកំណត់នូវភាពជោគជ័យឬបរាជ័យនៅក្នុងការងារដាំឈើ ហើយបញ្ហាទាំងនេះត្រូវតែដោះស្រាយឱ្យបានជ្រះស្រឡះដោយស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ។ កត្តាទាំងនោះមានដូចជាៈ

- ការគូសកំណត់ព្រំប្រទល់ ការចាត់ថ្នាក់ដីព្រៃឈើ ការបោះបង្គោលធ្វើព្រំប្រទល់ជាក់ស្តែងនូវដែនព្រៃការពារ ព្រៃផ្តល់ផល និងដែនព្រៃឈើដែលត្រៀមបំរុងសំរាប់បំរើគោលបំណងផ្សេង។
- សុវត្ថិភាពនៃការកាន់កាប់ដី និងការប្រើប្រាស់នូវធនធាននៃតំបន់នោះ
- បណ្តាលិខិតបទដ្ឋានផ្លូវច្បាប់សំរាប់គាំទ្រនានា / ផែនការអភិវឌ្ឍន៍នៅក្នុងតំបន់
- ការទទួលស្គាល់នូវតំលៃពិតនៃអនុផលព្រៃឈើ ផលិតផលនិងសេវាកម្មពីព្រៃឈើ ព្រមទាំងការចូលរួមចំណែករបស់វិស័យព្រៃឈើក្នុងវិស័យសេដ្ឋកិច្ចជាតិ
- គំរោងការសេដ្ឋកិច្ច ( ការផ្តល់ថវិកា ការបង់ពន្ធឬបន្ធូរបន្ថយពន្ធ ការលើកលែងពន្ធ ប្រាក់ឧបត្ថម្ភធន)
- សេវាកម្មផ្សព្វផ្សាយ ( ការប្រឹក្សាលើផ្នែកបច្ចេកទេស រួមទាំងតម្លៃឈើនៅលើទីផ្សារ និងគ្រាប់ពូជ)
- បណ្តាហេដ្ឋារចនាសម្ព័ន្ធ ( ផ្លូវថ្នល់ទៅកាន់ទីផ្សារ ការដឹកជញ្ជូន ទីផ្សារឈើក្នុងស្រុក និង ការនាំចេញ)